ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១៤៩៣ អពដ

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០១៥

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ) ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ចំនួន ៤០ រូប ដើម្បីបំពេញការងារជាបុគ្គលិកបញ្ចូលទិន្នន័យនៅអគ្គនាយកដ្ឋានពន្ធដារ ដែលនឹងត្រូវទទួលបានប្រាក់បៀវត្ស ចន្លោះចាប់ពី ៨០០ ០០០ រៀល ទៅ ១ ២០០ ០០០ រៀល (ប្រហែល ២០០ ទៅ ៣០០ ដុល្លារអាមេរិក) ក្នុងមួយខែ អាស្រ័យលើបទពិសោធន៍ និងជំនាញការងារជាក់ស្ដែងរបស់បេក្ខជន/បេក្ខនារី។

**ភារកិច្ច និងលក្ខខណ្ឌការងារដែលត្រូវជ្រើសរើស ÷**

*ភារកិច្ច ÷*

- បញ្ចូលទិន្នន័យបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាស និងទិន្នន័យអចលនទ្រព្យ គ្រប់ខេត្ត-ខណ្ឌ ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ។
- ផ្ទៀងផ្ទាត់ទិន្នន័យដែលបានបញ្ចូលរួច ជាមួយនឹងឯកសារសំណៅដើម និងឯកសារពាក់ព័ន្ធផ្សេងៗ។
- រៀបចំទុកដាក់ឯកសារសំណៅដើមតាមប្រភេទនិងតាមលំដាប់លំដោយ ហើយបញ្ជូនទៅឲ្យក្រុមការងារចុះបញ្ជី រក្សាទុកនៅមជ្ឈមណ្ឌលផ្ទុកឯកសារសំណៅដើម (Data Storage Center) របស់អគ្គនាយកដ្ឋានពន្ធដារ។
- បំពេញការងារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការបញ្ចូលទិន្នន័យដូចរៀបរាប់ខាងលើ តាមការចាំបាច់របស់អគ្គនាយកដ្ឋានពន្ធដារ។

*លក្ខខណ្ឌជ្រើសរើស÷*

បេក្ខជនទាំងពីរភេទ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ÷

- មានកម្រិតវប្បធម៌ សញ្ញាបត្របរិញ្ញាបត្រ ឬបរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូល
- មានជំនាញផ្នែកកុំព្យូទ័រ ច្បាស់លាស់ ជាពិសេស កម្មវិធី Microsoft Word, Excell, Access។ល។
- វាយអត្ថបទ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ក្នុងល្បឿនពី ៧០ ទៅ ១០០ ពាក្យ ក្នុងមួយនាទី
- អាន និងសរសេរភាសាខ្មែរ និងភាសាអង់គ្លេស បានល្អ
- មានបទពិសោធន៍ការងារផ្នែកបញ្ចូលទិន្នន័យ (Data Entry) យ៉ាងតិច ១ ឆ្នាំ
- មានជំនាញផ្នែករដ្ឋបាល កាន់តែប្រសើរ
- មានការទទួលខុសត្រូវខ្ពស់ចំពោះការងារ និងគោរពក្រមសីលធម៌វិជ្ជាជីវៈបានល្អ

- មិនប្រើប្រាស់ព័ត៌មានផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានពន្ធដារ ជាពិសេស ទិន្នន័យរបស់អ្នកជាប់ពន្ធ យកទៅបម្រើផលប្រយោជន៍ក្នុងគោលដៅផ្សេង ដោយមិនមានការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារ
- បេក្ខនារី ត្រូវបានជំរុញ និងទទួលការគាំទ្រក្នុងការដាក់ពាក្យចូលបម្រើការងារខាងលើ

**ព័ត៌មាននៃការដាក់ពាក្យសុំបម្រើការងារ**

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ និងមានសមត្ថភាពដូចរៀបរាប់ខាងលើ សូមសរសេរប្រវត្តិរូបសង្ខេប (CV) ដោយបិទភ្ជាប់ជាមួយនូវរូបថតបច្ចុប្បន្ន និងច្បាប់ថតចម្លងសញ្ញាបត្រដែលមាន ព្រមទាំងឯកសារផ្សេងៗដែលពាក់ព័ន្ធ (References) ហើយដាក់ជូននាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋាន អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី និងមហាវិថីម៉ៅសេទុង សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ៨៨៦ ៧២៤ ឬតាមរយៈអ៊ីម៉ែល nts@tax.gov.kh។ កាលបរិច្ឆេទឈប់ទទួលពាក្យ **ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ វេលាម៉ោង ១៧:០០ នាទី**។

**អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋាន ពន្ធដារ